ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 06 / 2015
ម៉ោង (Time/Heure) : 15:05
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

### សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

### ថ្ងៃ ចន្ទ ទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥

### សវនាការលើភ័ស្តុតាង - ថ្ងៃ ២៨៥

រៀបចំដោយ៖ **សែ កុលវុឌ្ឍី** និង **Maddalena GHEZZI**

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Maddalena GHEZZI |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicolas KOUMJIAN, លោក Vincent de Wilde d'ESTMAEL, លោក Dale LYSAK, លោក ស្រ៊ា រតនៈ |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក លឺវ សុវណ្ណា, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin Saunders |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោកស្រី ទ្រី ស៊ីនណា |
| សាក្សី/ដើមបណ្តឹង៖ លោកស្រី មាស ឡៃហួរ (2-TCW-851) |

| |
|---|
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ លោក វ៉ាត សុម៉ៅ, លោកស្រី ពេជ ចរិយា, កញ្ញា ស្រី ណាក់, កញ្ញា សុក សុភ័គមណីកា, លោក លី សុតុល្យ , លោក Yassir AL-KHUDAYRI |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០៩ | បញ្ចប់ម៉ោង៖ ១៦.០៦ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៤៨ | បញ្ចប់ម៉ោង៖ ១១.០៧ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣៧ | បញ្ចប់ម៉ោង៖ ១៣.៣៣ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤១ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២២ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៩ | ០៩.១២ |
| សំណើរបស់ នួន ជា ស្នើសុំចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.១២ | ០៩.១៤ |
| ការធ្វើសារណាផ្ទាល់មាត់ទាក់ទងនឹងការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មក្នុងសំណុំរឿង ០០២/០២ | សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្ដី នួន ជា<br>មេធាវីការពារក្ដី ខៀវ សំផន | ០៩.១៥<br>០៩.៤៨<br>១០.០២<br>១០.៣០ | ០៩.៤៨<br>១០.០២<br>១០.៣០<br>១០.៤៧ |
| ការតាំងសំណួរទៅសាក្សី មាស ឡៃហួរ (2-TCW-851) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១១.០៩<br>១១.១៥ | ១១.១៥<br>១៦.០៤ |
| សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់មេធាវីការពារក្ដី នួន ជា ស្នើសុំឱ្យមានការបញ្ជាក់ថាតើ ខ្មែរក្រោម ត្រូវបានរាប់បញ្ចូលជាក្រុមគោលដៅក្នុងសំណុំរឿង ០០២/០២ ដែរ ឬទេ | អង្គជំនុំជម្រះ | ១៣.៣៤ | ១៣.៣៨ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំចូលរួមកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការធ្វើសារណាផ្ទាល់មាត់ទាក់ទងនឹងការប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មក្នុងសំណុំរឿង ០០២/០២**

សហព្រះរាជអាជ្ញា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីការពារក្តី នួន ជា និងមេធាវីការពារក្តី ខៀវ សំផន បានធ្វើសារណាផ្ទាល់មាត់ទាក់ទងនឹងការប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្មក្នុងសំណុំរឿង ០០២/០២។

**ការតាំងសំណួរទៅសាក្សី មាស ឡៃហួរ (2-TCW-851)**

អង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួន ព្រមទាំងប្រាប់អំពីសិទ្ធិនិងករណីកិច្ចដល់សាក្សី មាស ឡៃហួរ (2-TCW-851)។ បន្ទាប់មក សហព្រះរាជអាជ្ញា បានធ្វើការតាំងសំណួរបន្តទៅសាក្សី។

**សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ស្នើសុំឱ្យមានការបញ្ជាក់ថាតើខ្មែរក្រោម ត្រូវបានរាប់បញ្ចូលជាក្រុមគោលដៅក្នុងសំណុំរឿង ០០២/០២ ដែរឬទេ**

អង្គជំនុំជម្រះបានសម្រេចថា ក្នុងសំណុំរឿង ០០២/០២ គឺមិនរាប់បញ្ចូលការចោទប្រកាន់ទាក់ទងនឹងការកំណត់គោលដៅលើខ្មែរក្រហមថាជាក្រុមជាក់លាក់មួយនោះទេ។ អង្គជំនុំជម្រះនឹងធ្វើការពិចារណាទៅលើភ័ស្តុតាងតាមករណីនីមួយៗ ដោយផ្អែកតាមក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក។ ជាគោលការណ៍ក្នុងករណីដែលភ័ស្តុតាងដែលបានស្នើឡើង ឬដែលបានពិភាក្សានូវចំពោះមុខអង្គជំនុំជម្រះ ជាប់ពាក់ព័ន្ធតែទៅនឹងការកំណត់គោលដៅទៅលើខ្មែរក្រោម ហើយដែលពាក់ព័ន្ធតែជាមួយនឹងការបង្កើតធាតុផ្សំនៃការធ្វើទុក្ខបុកម្នេញដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬ អំពើប្រល័យពូជសាសន៍ លើខ្មែរក្រោមទេនោះ អង្គជំនុំជម្រះយល់ថា វាមិនពាក់ព័ន្ធ ហើយនឹងមិនអនុញ្ញាតឱ្យធ្វើការដេញដោលឡើយ។ ហើយភ័ស្តុតាងដែលទាក់ទងនឹងខ្មែរក្រោមអាចពាក់ព័ន្ធនឹងបញ្ហាដទៃផ្សេងទៀតនៅក្នុងសំណុំរឿង ០០២/០២

ក្នុងករណីនេះ អង្គជំនុំជម្រះអាចអនុញ្ញាតឱ្យធ្វើការដេញដោលបាន។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

**Reclassified**

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/3857 | | 00070431-00071084; 00825261-00825338; 00850216-00850283 | Confession of Chor Chhan alias Sreng | P | 00070438 00070803 | 00825261 00825306 | 00850216 00850255 |
| E3/4202 | | 00858214-00858410; 00757471-00757568; 00849349-00849484 | Book by GINA Chon and THET Sambath entitled "Behind the killing fields: a Khmer Rouge leader and one of his victims" | P | | 00757520 | |
| E3/5264 | | 00271378-00271386; 00283339-00283346; 00333973-00333979 | Written Record of Interview of KÈ Un | P | 00271382 00271383 | 00283343 | 00333976 |

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9351 | D166/38 | 00239927-00239933; 00244161-00244166; 00283906-00283911 | Written Record of Interview of MEAS Laihuo | P | 00239929<br>00239930<br>00239931<br>00239932 | 00244162<br>00244163<br>00244164<br>00244165<br>00244166 | 00283907<br>00283908<br>00283909<br>00283910<br>00283911 |
| E3/8028 | D166/186 | 00347592-00347596; 00342223-00342225; 00345234-00345236 | Report of the Execution of Rogatory Letter, dated 01-05-2009: Site Identification Report | P | 00347592<br>00347495 | 00342223<br>00342225 | |

## Other documents (no change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E350/1 | | 01097947-01097962; 01097936-01097946 | Co-Prosecutors' Submission regarding the Application of the Torture Convention to S-21 confessions and other records relating to interrogations of prisoners | P | 01097958<br>01097959 | 01097943<br>01097944 | N/A |
| E3/1684 | | 00191816-00192089; 00192667-00192932; 00357247-00357451 | Book by DAVID Chandler entitled: "Voices from S-21 - Terror and History in Pol Pot's Secret Prison" | P | 00191882 | 00192726 | 00357313 |
| E313 | | 01006291-01007288; 01005661-01006290; 01004877-01005660 | Case 002/01 Judgement | P | 01006582<br>01006583<br>01006584 | 01005840<br>01005841 | 01005100<br>01005101 |
| E319/16 | | 01072139-01072151; 01072129-01072138 | NUON Chea's Motion in relation to Disclosures from Cases 003 and 004 and Response to the International Co- | P | | | N/A |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | prosecutor's Filing Providing Information in this Regard | | | | |
| E301/9/1.1 | | 00981692-00981700; 00981687-00981691; 00982092-00982097 | Annex: List of paragraph and portions of the Closing Order relevant to Case 002/02 | P | 00981694 | 00981688 | 00982093 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១៥)
- សេចក្តីសម្រេចលើសំណើរបស់ នួន ជា ធ្វើការបញ្ជាក់ថាតើ ខ្មែរក្រោម មិនត្រូវបានរាប់បញ្ចូលទៅក្នុងក្រុមគោលដៅក្នុងសំណុំរឿង ០០២/០២ ដែរ ឬទេ។ (១៣.៣៨)
- បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥។ (១៦.០៦)

**កាលវេលាសវនាការបន្ត**

សវនាការនឹងបន្តទៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ កុលទុ... Maddalena GHEZZI